ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
MINISTRY OF COMMERCE
នាយកដ្ឋាននីតិកម្ម
LEGAL AFFAIRS DEPARTMENT

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No.១៩៧១ MOC / M 2004 ✓

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៤

# សេចក្តីជូនដំណឹង
## ស្តីពី
## បែបបទទំនាក់ទំនង និង រយៈពេលចុះបញ្ជីពាណិជ្ជកម្ម នៅនាយកដ្ឋាននីតិកម្ម

អនុលោមតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម និង ប្រកាសលេខ 162 MOC/M 2004 ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការកំណត់សោហ៊ុយចំណាយលើបែបបទសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម សូមជូនដំណឹងដល់ក្រុមហ៊ុនពាណិជ្ជកម្ម ដែលមកសុំចុះបញ្ជីពាណិជ្ជកម្ម អោយបានជ្រាបអំពីបែបបទទំនាក់ទំនង និង រយៈពេលចុះបញ្ជីពាណិជ្ជកម្ម នៅនាយកដ្ឋាននីតិកម្មមានដូចតទៅ :

**ក-ដំណាក់កាលដំបូង** : អំពីទំនាក់ទំនងរៀបចំសំណុំលិខិត ( រយៈពេល ១ ថ្ងៃ )

**១-<u>អភិបាល ឬ ម្ចាស់ហ៊ុន</u>** : ចូលមកនាយកដ្ឋាននីតិកម្ម

-ប្រធាននាយកដ្ឋានបង្ហាញ និង ណែនាំតារាងសោហ៊ុយចំណាយ

-ផ្តល់ Form

-ផ្តល់លក្ខន្តិកៈគំរូ

-បញ្ជាឆែកនាមករណ៍

-អតិថិជនបង់សោហ៊ុយចំណាយ

**២-<u>មន្ត្រីចុះបញ្ជីពាណិជ្ជកម្ម</u>** : ទទួលបញ្ជាឆែកនាមករណ៍

-ឆែកនាមករណ៍ និង ផ្តល់យោបល់ជូនមកប្រធាននាយកដ្ឋាន

-រក្សាសិទ្ធិនាមករណ៍សំរាប់រយៈពេល ៣ ខែ

-ឆែកពាណិជ្ជសញ្ញា ( បើសិននាមករណ៍អាចសង្ស័យ )

-ជួយចុះព្រឹត្តប័ត្រពាណិជ្ជកម្ម

-ជួយបង់ប្រាក់ជូនសភាពាណិជ្ជកម្ម



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones (855-12) 933 323 881223

-ជួយបង់អាករ ( Tax ) ចូលថវិការរដ្ឋ

-ជួយបង់ប្រាក់ជូនមន្ទីរពាណិជ្ជកម្មក្រុងភ្នំពេញ

៣_**អតិថិជន ឬ ម្ចាស់ហ៊ុន :** រៀបចំសំណុំលិខិតគ្រប់គ្រាន់

-ថតចំលងអត្តសញ្ញាណប័ណ្ណ ៣ សន្លឹក

-រូបថត 4 x 6 ៣ សន្លឹក

-បំពេញ Form ៣ ច្បាប់

-រៀបចំលក្ខន្តិកៈ ៣ ច្បាប់

-តំកល់ប្រាក់ ៤,000,000 រៀល = 1,000 USD

-ធ្វើត្រា

**ខ_ដំណាក់កាលចុះបញ្ជីពាណិជ្ជកម្ម :** អំពីការអនុវត្តន៍ការចុះបញ្ជីពាណិជ្ជកម្ម ( រយៈពេល ១ថ្ងៃ )

៤_**អតិថិជន ឬ ម្ចាស់ហ៊ុន :** យកសំណុំលិខិតគ្រប់គ្រាន់មកប្រគល់ដល់នាយកដ្ឋាននីតិកម្ម ដើម្បីសុំធ្វើការចុះបញ្ជីពាណិជ្ជកម្ម ។ បើពិនិត្យឃើញថា សំណុំលិខិតមិនគ្រប់គ្រាន់ នាយកដ្ឋានទុកពេល ១៥ ថ្ងៃ ជូនដល់អតិថិជន សំរាប់កែសំរួលសំណុំលិខិត ឬ ឯកសារដែលមិនគ្រប់គ្រាន់នោះ ស្របតាមមាត្រា ២៥ ថ្មី នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ។ ក្នុងរយៈពេលយ៉ាងយូរ កន្លះថ្ងៃ ក្រោយពិនិត្យសំណុំលិខិតឃើញថា គ្រប់គ្រាន់ និង ត្រឹមត្រូវ លោកប្រធានការិយាល័យចុះបញ្ជីពាណិជ្ជកម្ម ផ្តល់យោបល់ និង បញ្ជូនសំណុំលិខិតទៅនាយកដ្ឋាន ដើម្បីផ្តល់យោបល់បន្ថែម ។

៥_ចាប់ពីពេលបានទទួលសំណុំលិខិត លោកប្រធាននាយកដ្ឋានពិនិត្យ និង ផ្តល់យោបល់បន្ថែម ក្នុងរយៈពេលយ៉ាងយូរ កន្លះថ្ងៃ រួចបញ្ជូនសំណុំលិខិតទៅអគ្គនាយកដ្ឋានបច្ចេកទេស ។

សេចក្តីជូនដំណឹងនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៤ តរៀងទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម_ប្រសិទ្ធ



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL: http://www.moc.gov.kh E-Mail: champrasidh@hotmail.com
Staff's Mobile Phones (855-12) 933 323 / 861223 Facsimile (855-23) 426396

# តារាង

## បែបបទទំនាក់ទំនង និង រយៈពេល

## ចុះបញ្ជីពាណិជ្ជកម្ម

ក - តំណាក់កាលដំបូង: ទំនាក់ទំនងរៀបចំសំណុំលិខិត

( រយៈពេល ១ ថ្ងៃ )

